ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

លេខ: ២៦៣ ប.ក

ភ្នំពេញ, ថ្ងៃទី០៧ ខែតុលា ឆ្នាំ ២០០៩

# ប្រកាស

## ស្តីពី

## ការធ្វើប្រតិភូកម្មមុខងារ និងភារកិច្ច ការងារវប្បធម៌ និងវិចិត្រសិល្បៈ ជូន ក្រុង ស្រុក គោលដៅ

## រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញ អនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញ សេចក្តីសម្រេចលេខ ១២ សសរ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពី ការបង្កើតការិយាល័យច្រកចេញ-ចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ

## ស ម្រេ ច

**ប្រការ ១ :** ត្រូវបានធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចការងារវប្បធម៌ និងវិចិត្រសិល្បៈ ជូន ក្រុង ស្រុក គោលដៅក្នុងក្របខណ្ឌនៃការចេញអាជ្ញាប័ណ្ណ ដើម្បីផ្តល់សេវាកម្មវប្បធម៌ និងវិចិត្រសិល្បៈដូចខាង ក្រោម :

- កម្មវិធីសម្តែងផ្សេងៗ (ក្រៅផ្លូវការ)
- ការបញ្ចាំងភាពយន្ត វីដេអូ

- អាជីវកម្មលក់ - ជួល ស្លាដៃភាពយន្តវីដេអូ
- ផ្លាកសញ្ញាអាជីវកម្មផ្សេងៗ
- អាជីវកម្មគ្រឿងបំពងសម្លេង
- អាជីវកម្មលក់-ជួល សៀវភៅ
- អាជីវកម្មសិល្បៈសូនរូប
- អាជីវកម្មថតរូប
- អាជីវកម្មកាត់សក់ អ៊ុតសក់ លំអក្រចក និងសំអាងការ

**ប្រការ ២ :** មន្ត្រីទទួលបន្ទុកការងារបច្ចេកទេសវប្បធម៌ ត្រូវរៀបចំគំរូបែបបទផ្សេងៗ រួមទាំងឯកសារពាក់ព័ន្ធសម្រាប់ការចេញអាជ្ញាប័ណ្ណទៅតាមការកំណត់ដូចបានចែងក្នុងប្រការ ១។

**ប្រការ ៣ :** ការអនុវត្តលើគំរូបែបបទផ្សេងៗ ដែលពាក់ព័ន្ធដល់ការចេញអាជ្ញាប័ណ្ណវប្បធម៌ របស់មន្ត្រីជំនួយការអភិបាលក្រុង ស្រុក គោលដៅ ត្រូវកំណត់ដោយសេចក្តីណែនាំមួយដោយឡែករបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

បញ្ជីលម្អិតរាយមុខសេវាកម្មវប្បធម៌ និងវិចិត្រសិល្បៈ ដែលត្រូវធ្វើប្រតិភូកម្មជូន ក្រុង ស្រុក គោលដៅ ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៤ :** ក្រុង ស្រុក គោលដៅ ត្រូវធ្វើរបាយការណ៍អំពីស្ថិតិនៃការផ្តល់អាជ្ញាប័ណ្ណសេវាកម្មវប្បធម៌ និងវិចិត្រសិល្បៈ ជារៀងរាល់ខែ តាមរយៈមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត មកក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**ប្រការ ៥ :** នាយកខុទ្ទកាល័យ អធិការ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ អគ្គនាយកដ្ឋានបេតិកភណ្ឌ ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត គោលដៅ និងមន្ត្រីទទួលបន្ទុកការងារវិសហមជ្ឈការ មានភារកិច្ចអនុវត្តនូវប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ភឿង សកុណា**

**ចម្លងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- សាលាខេត្ត គោលដៅ
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

លេខ:............០.៤.ស/ណន

ភ្នំពេញ, ថ្ងៃទី២៧..ខែតុលាឆ្នាំ ២០០៩

# សេចក្តីណែនាំ

## ការអនុវត្តខ្លឹមសារប្រកាសលេខ ២៦៣ ប្រ.ក ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០៩ ស្តីពី ការធ្វើប្រតិភូកម្មមុខងារ និងភារកិច្ច ការងារវប្បធម៌ និងវិចិត្រសិល្បៈ ជូន ក្រុង ស្រុក គោលដៅ

ផ្អែកលើខ្លឹមសារសេចក្តីសម្រេច លេខ ១២ សសរ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពី ការបង្កើតការិយាល័យច្រកចេញ ចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ។

ដើម្បីធានាបាននូវប្រសិទ្ធភាព និងលក្ខខណ្ឌចាំបាច់នៃការងារគ្រប់គ្រង និងអនុវត្តតាមខ្លឹមសារប្រកាសលេខ ២៦៣ ប្រ.ក ចុថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៩ ស្តីពី កាធ្វើប្រតិភូកម្មមុខងារ និងភារកិច្ច ការងារវប្បធម៌ និងវិចិត្រសិល្បៈ ជូន ក្រុង ស្រុក គោលដៅ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈសូមធ្វើការណែនាំដូចខាងក្រោម :

## I- អំពីបែបបទនៃការស្នើសុំប្រកបអាជីវកម្ម :

អតិថិជនដែលមានបំណងប្រកបអាជីវកម្ម ផលិតកម្ម សេវាកម្មវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវបំពេញទម្រង់បែបបទ ដូចខាងក្រោម :

- ពាក្យស្នើសុំ (មានបិទតែមប្រ៍).......................................... ០១ ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ច្បាប់ចម្លង)............................... ០១ ច្បាប់
- កិច្ចសន្យា....................................................................... ០១ ច្បាប់
- ប្លង់បង្ហាញទីតាំងអាជីវកម្ម..................................................... ០១ ច្បាប់
- រូបថត ទំហំ ៣ x ៤........................................................... ០៣ សន្លឹក
- បង្កាន់ដៃបង់ប្រាក់............................................................. ០១ ច្បាប់

ចំពោះការសុំអនុញ្ញាតប្រកបអាជីវកម្មបន្ត ទម្រង់បែបបទនេះត្រូវកាត់បន្ថយដោយគ្រាន់តែបំពេញនូវ :

- ពាក្យស្នើសុំ បន្ត(មានបិទតែមប្រ៍)............................................. ០១ ច្បាប់
- កិច្ចសន្យា បន្ត..................................................................... ០១ ច្បាប់
- បង្កាន់ដៃបង់ប្រាក់ ............................................................... ០១ ច្បាប់

## II- សេវាកម្មដែលត្រូវចេញលិខិតអនុញ្ញាត (សម្រាប់រយៈពេលខ្លី) :

១- ការប្រគំតន្ត្រីនៅទីសាធារណៈ (Concert)

២- ការសម្តែងទស្សនីយភាពល្ខោន (លក់សំបុត្រ)

៣- អាជីវកម្មរាំកំសាន្ត (លក់សំបុត្រ)

៤- ការបញ្ចាំងភាពយន្តវីដេអូ ផ្សាយពាណិជ្ជកម្ម

៥- ការបញ្ចាំងភាពយន្តវីដេអូកំដរពិធីបុណ្យផ្សេងៗ

៦- បណ្ណ័ប្រកាសផ្សាយពាណិជ្ជកម្ម (Poster)

៧- បដាផ្សាយពាណិជ្ជកម្ម

## III- សេវាកម្មដែលត្រូវចេញប័ណ្ណអនុញ្ញាត (សម្រាប់រយៈពេលវែង) :

១- ការបញ្ចាំងវីដេអូកំដរភ្ញៀវ តាមហាងកាហ្វេ និងភោជនីយដ្ឋាន

២- ហាងលក់-ជួល កាសែ្សត ស៊ីឌី វីស៊ីឌី ឌីវីឌី

៣- ការលើកផ្ទាំងយីហោគ្រប់ប្រភេទ

៤- ការលើកផ្ទាំងរូបភាព និងនិមិត្តសញ្ញាផ្សេងៗ

៥- ជួលធុងបាស និង ឧបករណ៍ឧគ្ឃោសនស័ព្ទ

៦- បណ្ណាគារ

៧- ទីតាំងផលិត និងលក់ចម្លាក់ពុម្ពស៊ីម៉ង់

៨- ជាងគំនូរ

៩- អគារថតរូប

១០- ផ្ទះថតរូប

១១- ហាងកាត់សក់ បុរស

១២- ហាងអ៊ុតសក់ កាត់សក់ លម្អក្រចក

១៣- ហាងសំអាងការ

## IV- គោលការណ៍ត្រួតពិនិត្យ :

ក- **ផ្នែកសិល្បៈទស្សនីយភាព** : ចំណុច $II_{១}$ . $II_{២}$ និង $II_{៣}$

- ខ្លឹមសារ និងទម្រង់សិល្បៈដែលយកមកប្រគំ ឬសម្តែងត្រូវតាមលក្ខណៈសមស្របទៅនិងប្រពៃណីទំនៀមទម្លាប់ជាតិ។
- រូបភាព និងទម្រង់សិល្បៈរបស់ជាតិមិនត្រូវច្នៃខុសពីលំនាំដើម។
- ការប្រគំ ឬសម្តែងរបស់ក្រុមសិល្បៈបរទេស ត្រូវមានការអនុញ្ញាតពីក្រសួង ឬមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត។

- ការប្រគំ ឬសម្តែង ដែលមានទិសដៅ អប់រំបំផុសចំណេះដឹងល្អដល់ប្រជាពលរដ្ឋត្រូវបានទទួលការលើកទឹកចិត្ត ។
- ការលួចយកស្នាដៃអ្នកដទៃមកសម្តែងត្រូវហាមឃាត់ ។

**ខ. <u>ផ្នែកស្នាដៃសោតទស្សន៍</u>** : ចំណុច $II_{៤}$ . $II_{៥}$ . $III_{១}$ និង $III_{២}$

គ្រប់ស្នាដៃភាពយន្ត និងវីដេអូ ជាកាសែ្សត ស៊ីឌី. វីស៊ីឌី. ឌីវីឌី ដែលយកមកដាក់លក់ ឬចាក់ផ្សាយត្រូវមានទិដ្ឋាការអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**គ. <u>ផ្នែកស្លាកសញ្ញាអាជីវកម្ម</u>** : ចំណុច $II_{៦}$ . $II_{៧}$ . $III_{៣}$ និង $III_{៤}$

- អក្សរត្រូវសរសេរឱ្យបានត្រឹមត្រូវតាមពាក្យពេចន៍ និងអក្ខរាវិរុទ្ធ ដោយអនុវត្តតាមវចនានុក្រមរបស់សម្តេចព្រះមហាសុមេធាធិបតី ជោតញ្ញាណោ ជួន ណាត ។
- ទំហំអក្សរខ្មែរត្រូវសរសេរធំជាងអក្សរបរទេស ហើយដាក់ជួរលើគេបង្អស់ ។
- អក្សរបរទេសត្រូវសរសេរនៅពីក្រោមដែលមានទំហំពាក់កណ្តាលនៃអក្សរខ្មែរ ។ ពាក្យពេចន៍អក្ខរាវិរុទ្ធនៃអក្សរបរទេសក៏ត្រូវសរសេរឱ្យបានត្រឹមត្រូវតាមភាសាជាតិនីមួយៗ ។
- ចំពោះពាណិជ្ជនាមអាចសរសេរជាអក្សរបរទេសទំហំធំបាន តែមិនអនុញ្ញាតឱ្យសរសេរអក្សរខ្មែរទំហំតូចជាង នៅពីក្រោមលើផ្ទាំងជាមួយគ្នាបានឡើយ ។
- រូបភាពការដាក់តាំងផ្សព្វផ្សាយផ្ទាំងឃ្លីហោ និមិត្តសញ្ញា និងផ្ទាំងផ្សាយពាណិជ្ជកម្មគ្រប់ប្រភេទត្រូវរក្សាឱ្យបាននូវសោភ័ណភាពដើម ។

**ឃ. <u>ផ្នែកសិល្បៈសូនរូប</u> <u>និង</u> <u>សិល្បៈសិប្បកម្ម</u>** : ចំណុច $III_{៧}$ . $III_{៨}$ . $III_{៩}$ និង $III_{១០}$

- រាល់ចម្លាក់ត្រូវគោរពឱ្យបានតាមបទដ្ឋានបច្ចេកទេស មានរចនាបថ ទម្រង់ និងខ្នាត ដែលជាលក្ខណៈប្រពៃណីជាតិ ។
- រាល់ស្នាដៃត្រូវមានកំណត់សម្គាល់ពីប្រភពផលិតច្បាស់លាស់ ។
- មិនត្រូវលក់ ដូរ ឬក្លែងបន្លំវត្ថុបុរាណដែលជាបេតិកភណ្ឌជាតិ ។
- មិនត្រូវយកវត្ថុបុរាណមកដាក់តាំងលាយឡំជាមួយផលិតផលថ្មី ។
- មិនត្រូវយករូបថតអតិថិជន ទៅធ្វើអាជីវកម្ម ឬសេវាកម្មទោះក្នុងរូបភាពអ្វីក៏ដោយ ដោយគ្មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ ។

**ង. <u>ផ្នែកអភិវឌ្ឍន៍វប្បធម៌</u>** : ចំណុច $III_{១១}$ . $III_{១២}$ និង $III_{១៣}$

ដើម្បីធានាដល់សុវត្ថិភាពរបស់អតិថិជន អាជីវករកាត់សក់ អ៊ុតសក់ លម្អក្រចក និងសំអាងការ ត្រូវ :

- ជៀសវាងការប្រើប្រាស់ កាំបិត ឬឡាមកោររួមគ្នា ។
- ត្រូវត្រួតពិនិត្យលក្ខណៈបច្ចេកទេស នៅរាល់សម្ភារៈប្រើប្រាស់ ។

- មិនត្រូវយក ទឹកថ្នាំ ឬសារធាតុផ្សេងៗដែលហួសកាលកំណត់ទៅប្រើប្រាស់ ។
- ការតុបតែងសំលៀកបំពាក់ និងគ្រឿងអលង្ការ ប្រពៃណី ឬបុរាណត្រូវគោរពតាមលក្ខណៈ ឬទម្រង់ដើមរបស់ជាតិ ។
- មិនត្រូវបំឡើងសម្លេងគ្រឿងឧបត្ថម្ភសនស័ព្ទខ្លាំងៗ រំខានដល់ជីវភាពរស់នៅ និងបរិស្ថានដែលនៅជុំវិញ ពិសេសរាល់រាត្រីត្រូវបញ្ឈប់នៅម៉ោង ២១(ម្ភៃមួយ) ។

ច. ផ្នែកសៀវភៅ : ចំណុច III.៦

- សៀវភៅគ្រប់ប្រភេទដែលយកមកដាក់លក់គឺ ជាសៀវភៅដែលមានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិដោយមានចុះចំនួនក្នុងបញ្ជីត្រឹមត្រូវ និងពីស្ថាប័នមានសមត្ថកិច្ចដែលច្បាប់បានកំណត់ ។
- សៀវភៅគ្រប់ប្រភេទ ជាអក្សរខ្មែរ ឬអក្សរបរទេសដែលលួចថតចម្លងមិនអាចដាក់លក់បានទេ ។

ខ្លឹមសារគោលការណ៍ត្រួតពិនិត្យខាងលើនេះ ត្រូវដាក់បញ្ចូលក្នុងកិច្ចសន្យានៃទម្រង់បែបបទស្នើសុំសេវាកម្មរបស់អតិថិជន ។

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សង្ឃឹមនិងជឿជាក់ថា មន្ត្រីទទួលខុសត្រូវគ្រប់លំដាប់ថ្នាក់នៅក្រុង ស្រុកគោលដៅរួមជាមួយអតិថិជន និងបានចូលរួមអនុវត្ត តាមខ្លឹមសារសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាពខ្ពស់សំដៅជំរុញ ការអនុវត្តប្រព័ន្ធរដ្ឋបាលថ្មីៗរបស់រាជរដ្ឋាភិបាលកម្ពុជា ឱ្យទទួលបានជោគជ័យជាស្ថាពរ ។

រដ្ឋមន្ត្រី

ភឿង សាកុណា

កន្លែងទទួល

- ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- ក្រសួងមហាផ្ទៃ
- សាលាខេត្ត គោលដៅ
- សាលាក្រុង ស្រុក គោលដៅ
- មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

# តារាងតម្លៃសេវាកម្មលើវិស័យ វប្បធម៌ និងវិចិត្រសិល្បៈ

| លក្ខណៈប្រតិបត្តិកម្ម | រាយមុខសេវាកម្ម | តម្លៃសេវាកម្ម | | | | | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|---|
| | | ពាក្យសុំបន្ទាន់វ៉ៃ | តែមប្រ៊ី | សេវាប្រតិបត្តិ | រយៈពេល | អាជ្ញាប័ណ្ណ | |
| កម្មវិធីសម្តែងផ្សេងៗ (ក្រៅផ្លូវការ) | -ការប្រគំតន្ត្រីនៅទីសាធារណៈ | ១.០០០៛ | ២.០០០៛ | ៩៧.០០០៛ | ១ លើក | លិខិតអនុញ្ញាត | ១០០.០០០៛ |
| | -ការសម្តែងទស្សនីយភាពល្ខោន លក់សំបុត្រ | ១.០០០៛ | ២.០០០៛ | ១២.០០០៛ | ១ លើក | លិខិតអនុញ្ញាត | ១៥.០០០៛ |
| | -អាជីវកម្ម រាំកំសាន្ត លក់សំបុត្រ | ១.០០០៛ | ២.០០០៛ | ១២.០០០៛ | ១ ថ្ងៃ | លិខិតអនុញ្ញាត | ១៥.០០០៛ |
| ការបញ្ចាំងភាពយន្ត វីដេអូ | - ការបញ្ចាំងភាពយន្ត វីដេអូ ផ្សាយពាណិជ្ជកម្ម | ១.០០០៛ | ២.០០០៛ | ១២.០០០៛ | ១ ថ្ងៃ | លិខិតអនុញ្ញាត | ១៥.០០០៛ |
| | - ការបញ្ចាំងភាពយន្ត វីដេអូ កំដរពិធីបុណ្យផ្សេងៗ | ១.០០០៛ | ២.០០០៛ | ១២.០០០៛ | ១ ថ្ងៃ | លិខិតអនុញ្ញាត | ១៥.០០០៛ |
| | - ការបញ្ចាំងភាពយន្ត វីដេអូ កំដរភ្ញៀវ | ៣.០០០៛ | ២.០០០៛ | ២១.០០០៛ | ១ ឆ្នាំ | ប័ណ្ណអនុញ្ញាត | ២៦.០០០៛ |
| អាជីវកម្មលក់ ជួលស្លាដែភាពយន្ត វីដេអូ | -ហាងលក់ ជួល ស៊ីឌី វីស៊ីឌី ឌីវីឌី | ៣.០០០៛ | ២.០០០៛ | ២១.០០០៛ | ១ ឆ្នាំ | ប័ណ្ណអនុញ្ញាត | ២៦.០០០៛ |
| ស្លាកសញ្ញាអាជីវកម្ម | -ផ្ទាំងឃីហោ គ្រប់ប្រភេទ | ៣.០០០៛ | ២.០០០៛ | ៤៧.០០០៛ | ២ ឆ្នាំ | ប័ណ្ណអនុញ្ញាត | ៥០.០០០៛ |
| | - បណ្ណ័ប្រកាសផ្សាយពាណិជ្ជកម្ម (Poster) | ១.០០០៛ | ២.០០០៛ | ២៣.០០០៛ | ៣ ខែ | លិខិតអនុញ្ញាត | ១៥.០០០៛ |
| | - ផ្ទាំងរូបភាព - និមិត្តសញ្ញាផ្សេងៗ | ៣.០០០៛ | ២.០០០៛ | ៤៥.០០០៛ | ២ ឆ្នាំ | ប័ណ្ណអនុញ្ញាត | ៥០.០០០៛ |
| | - បដាផ្សាយពាណិជ្ជកម្ម | ១.០០០៛ | ២.០០០៛ | ១២.០០០៛ | ៣ ខែ | លិខិតអនុញ្ញាត | ១៥.០០០៛ |
| អាជីវកម្មគ្រឿងបំពងសម្លេង | - ជួលធុងបាស់ និង ឧបករណ៍សូរស័ព្ទ | ៣.០០០៛ | ២.០០០៛ | ៣.០០០៛ | ១ ឆ្នាំ | ប័ណ្ណអនុញ្ញាត | ៨.០០០៛ |
| អាជីវកម្មលក់សៀវភៅ | - បណ្ណាគារ | ៣.០០០៛ | ២.០០០៛ | ៣៥.០០០៛ | ១ ឆ្នាំ | ប័ណ្ណអនុញ្ញាត | ៤០.០០០៛ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| អាជីវកម្មសិល្បៈសូនរូប | - ទីតាំងផលិត និងលក់ចម្លាក់ ពុម្ពស៊ីម៉ង់ | ៣.០០០៛ | ២.០០០៛ | ៣៥.០០០៛ | ១ ឆ្នាំ | ប័ណ្ណអនុញ្ញាត | ៤០.០០០៛ |
| | - ជាង គំនូរ | ៣.០០០៛ | ២.០០០៛ | ២១.០០០៛ | ១ ឆ្នាំ | ប័ណ្ណអនុញ្ញាត | ២៦.០០០៛ |
| អាជីវកម្ម ថតរូប | - អាគារថតរូប ( មានស៊ីឌីយូ) | ៣.០០០៛ | ២.០០០៛ | ៣៥.០០០៛ | ១ ឆ្នាំ | ប័ណ្ណអនុញ្ញាត | ៤០.០០០៛ |
| | - ផ្ទះថតរូប | ៣.០០០៛ | ២.០០០៛ | ២១.០០០៛ | ១ ឆ្នាំ | ប័ណ្ណអនុញ្ញាត | ២៦.០០០៛ |
| អាជីវកម្មកាត់សក់ អ៊ុតសក់ លម្អក្រចក និងសំអាងការ | - ហាង កាត់សក់ បុរស | ៣.០០០៛ | ២.០០០៛ | ១៥.០០០៛ | ១ ឆ្នាំ | ប័ណ្ណអនុញ្ញាត | ២០.០០០៛ |
| | - ហាងអ៊ុតសក់ - កាត់សក់ - លម្អក្រចក | ៣.០០០៛ | ២.០០០៛ | ៣៥.០០០៛ | ១ ឆ្នាំ | ប័ណ្ណអនុញ្ញាត | ៤០.០០០៛ |
| | - ហាង សំអាងការ | ៣.០០០៛ | ២.០០០៛ | ៤៥.០០០៛ | ១ ឆ្នាំ | ប័ណ្ណអនុញ្ញាត | ៥០.០០០៛ |

...ភ្នំពេញ... ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១០

**តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

គង់.ហុង

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៩

**រ ដ្ឋ ម ន្ត្រី**

ហ៊ឹម.ឆែម